ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ១២២ / ១៣-០២-២០១៣
សាលដីកា
លេខ៩៣ "ក្រ២ង"
ចុះថ្ងៃទី១៣-១១-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទីសាមសិបមួយ ខែតុលា ឆ្នាំពីរពាន់ដប់បី ដូចខាងក្រោមៈ

## ក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ១២២ ចុះថ្ងៃទី១៣-០២-២០១៣ រវាងៈ

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ[redacted] ។ ទីលំនៅភូមិទីក[redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុខគ្មាន ។ (ប្តឹងឧទ្ធរណ៍)

ឃុំខ្លួន ថ្ងៃទី ២៩-០៧-២០១២ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ១៣០១ តព្រ ចុះថ្ងៃទី ២៩-០៧-២០១១។

-មេធាវីការពារ លោក[redacted]វិបុល

<u>ជាប់ចោទពីបទ:</u> លួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ

ប្រព្រឹត្តនៅចំណុចផ្ទះលេខ៣៩CHE$_0$E$_1$ ផ្លូវលេខ២៦៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ

ទីលំនៅ[redacted]
[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ។

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ២៧-កក្កដា-២០១២ វេលាម៉ោងប្រហែល ១រំលងអាធ្រាត្រ ជនរងគ្រោះឈ្មោះ [redacted] ចាន់ធន បានជិះម៉ូតូម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរី២០០៥ ទៅទុកនៅផ្ទះជាន់ខាងក្រោម គឺផ្ទះលេខ៣៥CHE$_0$E$_1$ ផ្លូវលេខ២២៦៥ ក្រុម៦ ភូមិ២ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ដោយបានចាក់សោរទ្វាររបង និងចាក់សោរម៉ូតូ ហើយជនរងគ្រោះក៏បានឡើងទៅដេកនៅលើផ្ទះតែម្តង ។ បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] វណ្ណា ក៏បានយកដែកចុងស្រួចមកចាក់គាស់បំបែកសោរទ្វារផ្ទះជាន់ក្រោមនោះ ហើយចូលទៅលួចយកបានទ្រព្យសម្បត្តិរបស់ជនរងគ្រោះ រួមមានៈ ម៉ូតូ, កង់, ទូរស័ព្ទដៃ និង ប្រាក់ ទៀតផង ។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយសារភាពថា ៖ កាលពីថ្ងៃទី ២៧-កក្កដា-២០១២ វេលាម៉ោងប្រហែល ១រំលងអាធ្រាត្រ ខ្លួនពិតជាបានធ្វើសកម្មភាពឆ្កឹះសោរទ្វារផ្ទះរបស់គេដើម្បីចូលទៅលួចយក កង់, ម៉ូតូ, ទូរស័ព្ទដៃ និង ប្រាក់ របស់ជនរងគ្រោះប្រាកដមែន ។ ខ្លួនធ្វើសកម្មភាពឆ្កឹះសោរទ្វារផ្ទះនោះតែម្នាក់ឯងទេ ដោយខ្លួនបានប្រើឧបករណ៍រួមមានៈ កាំកង់ និង កន្ត្រៃ ។

-បានឃើញចម្លើយជនរងគ្រោះឈ្មោះ [redacted] ចាន់ធន បានឆ្លើយថា ៖ កាលពីថ្ងៃទី ២៧-កក្កដា-២០១២ ខ្លួនបានជិះម៉ូតូចូលទៅក្នុងផ្ទះដោយបានចាក់សោរកម៉ូតូ និងសោរទ្វារបន្ទប់ផ្ទះត្រឹមត្រូវទៀតផង។ រីឯ កង់មួយគ្រឿងទុកនៅខាងក្រោមក្រៅបន្ទប់។ ក្រោយពីឮសំឡេងស្រែកទើបខ្លួនដឹងថាៈ មេសោរពីរដាច់កញ្ចក់ទ្វារចង្ក្រានបាយត្រូវបានដោះចេញ និងមានការបាត់ ម៉ូតូ, កង់, ទូរស័ព្ទដៃ និង ប្រាក់ ។ នៅក្នុងរឿងនេះ គឺខ្លួនប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ១.០០០ (មួយពាន់)ដុល្លាអាមេរិក ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១២២ ក្រ៦ "ប" ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តី ដែលមានខ្លឹមសារដូចតទៅ ៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ២៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ ។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយការកាប់គាស់ទម្លុះទម្លាយ ប្រព្រឹត្តនៅចំណុចផ្ទះលេខ ៣៥CHE$_0$E$_1$ ផ្លូវលេខ២២៦៥ ក្រុម៦ ភូមិ២ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ។

បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

២-បង្គាប់ឱ្យឈ្មោះ [redacted] វណ្ណា សងការខូចខាតចំនួន ១.០០០.០០០ (មួយលាន)រៀល ឱ្យទៅឈ្មោះ [redacted] ចាន់ធន ។ ការទាមទារលើសពីនេះបដិសេធចោល ។ តាមមាត្រា ២៣ និងមាត្រា ៣៥៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣-វត្ថុចាប់យក រួមមាន :

ក-កន្ត្រៃដែក ដងជ័រពណ៌ក្រហម ចំនួនមួយ ។

ខ-ដែកចុងស្រួចសម្រាប់ចាក់ឆ្កឹះគ្រាប់សោរ ចំនួនមួយ ។

គ-ដែកជ្រុងរាងអក្សរអ៊ិល L ចំនួនមួយ ។

ឃ-កូនសោរ ចំនួនប្រាំមួយ ។

ត្រូវរឹបអូសបំផ្លាញចោល ។

៤-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]វណ្ណា និងចំពោះមុខជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចាន់ធន ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

*បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ៦៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] វណ្ណា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៧២ ក្រ៦ "ប" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ត្រង់ចំណុច សេចក្តីសម្រេចទាំងមូល ។*

-បានឃើញ របាយការណ៍របស់សាលាឧទ្ធរណ៍

-បានឃើញ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ

-ជនជាប់ចោទឈ្មោះ [redacted]វណ្ណា បានឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍ដើម្បីសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនព្រោះខ្លួនទទួលកំហុសហើយៗការប្រព្រឹត្តរបស់ខ្លួនមានតែម្នាក់ឯងទេ ពុំមានបក្សពួកឡើយ ។ នៅពេលនេះ ខ្លួនសំណូមពរ សុំលោកប្រធានជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ នៅក្នុងរឿងនេះ តាមចម្លើយរបស់ជនជាប់ចោទ និងរបស់ជនរងគ្រោះ មានភាពស៊ីសង្វាក់គ្នា ហើយជនជាប់ចោទបានឆ្លើយសារភាព ។ ដូច្នេះ សូមុតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានៈ នៅក្នុងរឿងនេះ កូនក្តីខ្លួនបានប្តឹងឧទ្ធរណ៍ដោយសារសាលាដំបូងសម្រេចដាក់ពន្ធនាគារច្រើនពេក ។ កូនក្តីខ្លួនបានឆ្លើយសារភាពគ្រប់ជាន់ថ្នាក់ ។ រឿងនេះកូនក្តីខ្លួនពិតជាបានលួចមែន គឺកង់ និងម៉ូតូ បានប្រគល់ឲ្យទៅម្ចាស់គេវិញហើយ ចំណែកទូរស័ព្ទ គឺប្រជាជនយកអស់ហើយ ។ បទល្មើសនេះមានកំរិតទណ្ឌកម្មពី ០៣ ទៅ ១០ឆ្នាំ ដូច្នេះ សូមក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនក្នុងកំរិតអប្បបរមា ព្រោះកូនក្តីខ្លួនពុំសូវចេះអក្សរទេ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ៦៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted]វណ្ណា បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៧២ ក្រ៦ "ប" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះ

បាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពឆ្កិះសោរទ្វារផ្ទះរបស់ជនរងគ្រោះ ដើម្បីចូលលួចទ្រព្យសម្បត្តិពិតប្រាកដមែន ។ ចំពោះសំណង ខ្លួនសុខចិត្តសង ប៉ុន្តែតុលាការដាក់ទោសខ្លួនច្រើនពេក សុំបន្ធូរបន្ថយទោស ។

៣-តំណាងមហាអយ្យការបានសន្និដ្ឋានថា ជនជាប់ចោទបានឆ្លើយសារភាព ។ សូមតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៤-មានពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] វណ្ណា ពីបទៈលួច មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ៣៥CHE₀E₁ ផ្លូវលេខ២៦៥ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៥-សំអាងហេតុ និងសម្រេចក្តីសម្រេចនៃសាលក្រមលេខ១២២ ក្រ៦ "ប" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១២ របស់សាលារាជធានីភ្នំពេញ បានសម្រេចសេចក្តីត្រឹមត្រូវហើយ ។ គប្បីតម្កល់ទុកជាបានការ ។

## **ហេតុដូច្នេះ**
## **វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៦៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] វណ្ណា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់ ប៉ុន្តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១២២ ក្រ៦ "ប" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] វណ្ណា តាមនីតិវិធី ។

៤-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ។ បើកសិទ្ធិប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

*សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តតាមសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរតាមច្បាប់ ។*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធាន |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted] | [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣
ក្រឡាបញ្ជី

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]



៣៧៥